ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# សន្ទរកថា

## ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការសម្របសម្រួលមូលនិធិសកលប្រចាំកម្ពុជា ថ្លែងនៅក្នុងកិច្ចបើកកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ នៃក្រុមប្រជាជនរងការប៉ះពាល់ជាងគេ ក្រុមប្រជាជនរស់នៅជាមួយជំងឺ និង អង្គការសាសនា

សណ្ឋាគារ ហ៊ីមាហារី

ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥

- *លោកស្រី* Inga Oleksy, *មន្ត្រីសម្របសម្រួលទំនាក់ទំនងមូលនិធិសកលរបស់* USAID
- *លោកស្រី* Marie-Odile Emond, *ប្រធានអង្គការ* UNAIDS *ប្រចាំកម្ពុជា*
- *លោកស្រី* Miled Goddard, *ទីប្រឹក្សារបស់* KAP

ជាការប្រសើរណាស់ដែលខ្ញុំបានស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាសារជាថ្មីម្តងទៀតនាថ្ងៃនេះ។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០១៤ រហូតដល់ពេលនេះ គណៈកម្មាធិការសម្របសម្រួលមូលនិធិសកលប្រចាំ កម្ពុជាបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ និង ពិភាក្សា ដោយមានការចូលរួមពីសំណាក់បងប្អូនពីសហគមន៍៖

ពីខែឧសភា ២០១៤ ដល់ខែមករា ឆ្នាំ២០១៥ យើងមានកិច្ចប្រជុំពិគ្រោះយោបល់ផ្សេងៗគ្នា កិច្ចពិភាក្សាថ្នាក់ជាតិជាមួយផ្នែកពាក់ព័ន្ធនានា និងកម្មវិធីជាតិ ដើម្បីអោយយើងបានដឹងបញ្ហាទាំងឡាយ តម្រូវការ និងអាទិភាពរបស់បងប្អូនពេលចងក្រង ឯកសារបង្ហាញទស្សនៈទានសំរាប់គំរោងជំនួយប្រយុទ្ធនឹងជំងឺរបេង អេដស៍

គ្រុនចាញ់ និង ពង្រឹងប្រព័ន្ធសុខាភិបាល។ ខ្ញុំមានក្តីសោមនស្សរីករាយ ជំរាបជូនបងប្អូនថា ឯកសារបង្ហាញទស្សនៈទានទាំងបួនរបស់ព្រះរាជាណាចក្រកម្ពុជា យើងត្រូវបានទទួលយកដោយជោគជ័យដោយគណៈកម្មការត្រួតពិនិត្យបច្ចេកទេស សំណើគំរោងនៃមូលនិធិសកល បន្ទាប់ពីបានកែសម្រួលបន្តិចបន្តួចតាមការស្នើសុំរបស់គណៈកម្មការត្រួតពិនិត្យបច្ចេកទេសសំណើគំរោងមូលនិធិសកល។

ខ្ញុំក៏ចងចាំដែរថា បងប្អូនទាំងអស់គ្នាបានជួបជុំគ្នាកាលពីខែមេសាកន្លងទៅស្តាប់អំពីកម្មវិធី សម្មភាពនានា ឧបត្ថម្ភគាំទ្រដោយមូលនិធិសកលដើម្បីបងប្អូនបានដឹងនិងទទួលព័ត៌មានអំពីសេវាកម្មនានាដែលត្រូវបានផ្តល់ជូននៅក្នុងខេត្ត និង សហគមន៍របស់បងប្អូន ខ្ញុំរំពឹងយ៉ាងមុតមាំថា បងប្អូនអាចបន្តចែកចាយព័ត៌មានទាំងអស់នេះ ដល់សមាជិករបស់បងប្អូនក្នុងឋានៈបងប្អូនជាតំណាងរបស់ពួកគាត់ស្របតាមក្តីរំពឹងរបស់យើងទាំងអស់គ្នា អំពីតួនាទីចំបងនៃអ្នកតំណាង និង អ្នកសម្របសម្រួលនៅក្នុងគណៈកម្មាធិការសម្របសម្រួលមូលនិធិសកលប្រចាំកម្ពុជា ។

ព្រឹកនេះ យើងនឹងស្តាប់អំពីផែនការនានារបស់ដៃគូអភិវឌ្ឍរបស់យើងគឺទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិរបស់សហរដ្ឋអាមេរិក មូលនិធិប្រធានាធិបតីសហរដ្ឋអាមេរិកសំរាប់គំរោងសកម្មភាពបន្ទាន់ប្រយុទ្ធនឹងជំងឺអេដស៍ **ផេបហ្វា** (PEPFAR: President's Emergency Plan for AIDS Relief)។ ដៃគូអភិវឌ្ឍនេះ គឺជាដៃគូរដើរតួដ៏សកម្មរួមជាមួយរាជរដ្ឋាភិបាលកម្ពុជានិងមូលនិធិសកលប្រយុទ្ធនឹងជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជា និងជួយកម្ពុជាយើងសំរេចបាននូវគោលដៅជាតិយើង។ ខ្ញុំសង្ឃឹមថា បងប្អូននឹងអាចផ្តល់ព័ត៌មានត្រឡប់និងគំនិតតបទៅនឹងបទបង្ហាញទាំងឡាយរបស់ដៃគូ ដើម្បីអោយផែនការនិងគំរោងកម្មវិធីរបស់ដៃគូនៅកម្ពុជាបន្តឆ្លើយតបទៅនឹងតម្រូវការ និង អាទិភាពរបស់សហគមន៍ដែលត្រូវការបំផុត និង សំរេចបានផលវិជ្ជមានកាន់តែទូលំទូលាយ។

នៅរសៀលថ្ងៃនេះ បងប្អូនក៏នឹងមានឱកាសស្តាប់អំពីផែនការ និងសកម្មភាព (បង្ហាញជូនដោយ **ឯកឧត្តម ធា ផល្លា**) របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដែលដោះស្រាយឧបសគ្គផ្លូវច្បាប់នានាដើម្បីជួយអោយការអនុវត្តកម្មវិធីជំងឺប្រយុទ្ធនឹងជំងឺអេដស៍ដោយមានប្រសិទ្ធភាព និងបង្កើនការខិតជិតទៅសេវាដែលនៅក្នុង

តំបន់របស់បងប្អូន។ ខ្ញុំយល់ថា មានបញ្ហាប្រឈម ប៉ុន្តែខ្ញុំជឿជាក់ថាកិច្ចពិភាក្សាបន្ត ជាមួយបងប្អូនទាំងអស់គ្នា នឹងជួយអោយអាជ្ញាធរជាតិសម្រេចបានគោលដៅរបស់ អាជ្ញាធរសំរាប់បងប្អូនប្រជាពលរដ្ឋរងការប៉ះពាល់ជាងគេ និង បងប្អូនប្រជាពលរដ្ឋ ដែលរស់នៅជាមួយជំងឺក្នុងការដោះស្រាយបំបាត់ឧបសគ្គផ្លូវច្បាប់នៅកម្ពុជា។

ខ្ញុំក៏សូមសសើរវត្តមានចូលរួមដ៏មានតំលៃរបស់តំណាង អង្គការសាសនា ក្រុម របស់បងប្អូន គឺជាផ្នែកមួយដ៏សំខាន់នៃយន្តការជួយការពារការចម្លងមេរោគ អេដស៍ របេង គ្រុនចាញ់ នៅទីក្រុងនិងតំបន់ជនបទដាច់ស្រយាល។ ខ្ញុំសង្ឃឹមថា បងប្អូននឹង បន្តដឹងអំពីសេវានានាដែលមាននៅក្នុងប្រទេស អ្នកនឹងអាចជួយចែករំលែកព័ត៌មាន ទាំងនេះជូនទៅបងប្អូនប្រជាពលរដ្ឋរស់នៅតំបន់ដែលបងប្អូនមានឥទ្ធិពលផ្សព្វផ្សាយ ដូចជាវត្តអារាម ព្រះវិហាគ្រឹះស្តសាសនា សាសនាឥស្លាមទាំងអស់ យើងអាចត្រួតត្រា ឬ កំហិតមិនអោយឆ្លងរាលដាលជំងឺទាំងនេះបាន។

ថ្ងៃនេះ បងប្អូននឹងមានពេលវេលាខ្លះស្តាប់របាយការណ៍ប្រចាំឆ្នាំអំពីសមិទ្ធិផល របស់សហគមន៍តំណាងនៅក្នុងគណៈកម្មាធិការសម្របសម្រួលមូលនិធិសកល ប្រទេសកម្ពុជា និងការរៀបចំសំរាប់ការបោះឆ្នោតជ្រើសរើសសមាជិករបស់គណៈកម្មាធិការសម្របសម្រួលមូលនិធិសកលប្រទេសកម្ពុជានៅខែវិច្ឆិកា បងប្អូននឹងត្រូវបាន ជំរាបជូនអំពីលក្ខ័ខ័ណ្ឌវិនិច្ឆ័យ និង ដំណើការជ្រើសរើសដែលគណៈកម្មាធិការសម្រប សម្រួលមូលនិធិសកលប្រទេសកម្ពុជាត្រូវអនុវត្តដើម្បីធានាតំបន់ផ្នែករបស់បងប្អូនត្រូវ បានតំណាងដោយសមស្របនៅក្នុង គណៈកម្មាធិការសម្របសម្រួលមូលនិធិសកល ប្រទេសកម្ពុជា។ ខ្ញុំសូមរំលេចជូនថា ការចូលរួមដ៏សកម្មរបស់បងប្អូនគឺតំណាង និង បំពេញសេចក្តីត្រូវការរបស់សមាជិករបស់បងប្អូន នៅក្នុងការការដំណើការនិងការ ប្រព្រិត្តទៅរបស់ គណៈកម្មាធិការសម្របសម្រួលមូលនិធិសកលប្រទេសកម្ពុជា និង ការចែកចាយព័ត៌មានត្រឡប់ជូនទៅសមាជីករបស់បងប្អូនវិញ គឺជាលក្ខ័ខ័ណ្ឌ អប្បរមាតម្រូវដោយមូលនិធិសកល នៅក្នុងទម្រង់ផ្តល់ហិរញ្ញប្បទានថ្មី របស់មូលនិធិសកល។ លក្ខ័ខ័ណ្ឌអប្បរមាតម្រូវដោយមូលនិធិសកលចាប់មានប្រសិទ្ធភាពអនុវត្តពីឆ្នាំ២០១៥ នេះតទៅ។

ដូច្នេះខ្ញុំរំពឹងថា យើងនឹងបន្តសម្រេចជោគជ័យបំពេញលក្ខខ័ណ្ឌតម្រូវរបស់មូលនិធិសកលដូចដែលយើងបានសម្រេច កម្ពុជាបំពេញបានកន្លងមកក្នុងការឆ្លើយតបទៅនឹងលក្ខខ័ណ្ឌតម្រូវរបស់មូលនិធិសកលកាលពីពេលកន្លងទៅ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណដល់ដៃគូទាំងអស់ ទីប្រឹក្សាបច្ចេកទេស ជាពិសេសទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិរបស់សហរដ្ឋអាមេរិក ប្រចាំនៅកម្ពុជាសំរាប់ការឧបត្ថម្ភគាំទ្រពង្រឹង ក្រុមបងប្អូនប្រជាជនដែលរងការប៉ះពាល់ជាងគេ អ្នករស់នៅជាជំងឺ និងក្រុមទ្រទ្រង់សាសនាសំរាប់ការចូលរួមដ៏សកម្មរបស់ពួកគេ នៅក្នុងគណៈកម្មាធិការសម្របសម្រួលមូលនិធិសកលប្រទេសកម្ពុជា។

ខ្ញុំសូមប្រកាសបើក កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិនៃក្រុមប្រជាជនរងការប៉ះពាល់ជាងគេ ក្រុមប្រជាជនរស់នៅជាមួយជំងឺ និង អង្គការសាសនា ចាប់ពីពេលនេះតទៅ។

សូមអរគុណ !!!